ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៩៧ ព.ណ.នគ.បក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" តាមប្រព័ន្ធស្វ័យប្រវត្តកម្ម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១១២ MOC/SM 2013 ចុះថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៣៣ ព.ណ បអព.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទ នាំចេញទំនិញទៅក្រៅប្រទេស
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។
- បានឃើញប្រកាសលេខ១៦១ ព.ណ ពពក.ប្រក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យអនុវត្តសាកល្បងនូវការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១ :**

ត្រូវបានដាក់ឲ្យអនុវត្តនូវការបំពេញបែបបទស្នើសុំ និងផ្តល់ការយល់ព្រមលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" (Form A) តាមប្រព័ន្ធស្វ័យប្រវត្តកម្ម (Automation System) សំដៅសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងបំពេញបានតាមលក្ខខណ្ឌតម្រូវវិធានប្រភពដើមទំនិញរបស់ប្រទេសនាំចូល។

**ប្រការ ២ :**

ផលិតករ ឬអ្នកនាំចេញទាំងអស់ ដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ទម្រង់ "អេ" ត្រូវចុះឈ្មោះសុំប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម តាមរយៈគេហទំព័រ "www.certificateoforigin.moc.gov.kh" របស់ក្រសួងពាណិជ្ជកម្ម ដោយបញ្ចូល(Upload)ព័ត៌មាន និងឯកសារតម្រូវទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ដូចខាងក្រោម:

- ឈ្មោះក្រុមហ៊ុន និងអាសយដ្ឋាន
- លិខិតបញ្ជាក់ពីការចុះបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
- ចុះឈ្មោះមុខទំនិញនាំចេញ
- តារាងថ្លៃដើមផលិតផល (cost breakdown) ឬឯកសារយោងតាមការកំណត់របស់វិធានប្រភពដើមទំនិញ
- លិខិតប្រគល់សិទ្ធិ និងលិខិតផ្ទេរសិទ្ធិ ពីប្រធានក្រុមហ៊ុន ឬនាយកគ្រប់គ្រង អនុញ្ញាតឲ្យចុះហត្ថលេខាលើពាក្យសុំ និងលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកប្រគល់សិទ្ធិ និងទទួលសិទ្ធិ និងរូបថតទំហំ ៤x៦ ចំនួន ០១សន្លឹក
- ឯកសារផ្សេងៗទៀត តាមការកំណត់ដោយបញ្ញត្តិច្បាប់

**ប្រការ ៣ :**

ផលិតករ ឬអ្នកនាំចេញទាំងអស់ ដែលបានចុះឈ្មោះសុំប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មរួចហើយ អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" តាមប្រព័ន្ធស្វ័យប្រវត្តកម្មឲ្យបានមុនកាលបរិច្ឆេទចេញទំនិញពីកម្ពុជា និងត្រូវភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម:

- វិក័យប័ត្រ (Invoice)
- តារាងវេចខ្ចប់ (Packing List)
- របាយការណ៍របស់មន្ត្រីជំនាញ អំពីសង្វាក់ផលិតកម្ម និងទំនិញនាំចេញដែលមានពណ៌ប៉ារ៉ាពណ៌បៃតង(ត្រេអ៊ី និងកាគី) និងទំនិញដែលដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនកម្ពុជាទៅឡើងយន្តហោះនៅប្រទេសជិតខាង (Land-Air)

**ប្រការ ៤ :**

នៅពេលដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម ផលិតករ ឬអ្នកនាំចេញត្រូវទូទាត់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារ ផ្អែកតាមការកំណត់ក្នុង

ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន ឬលិខិតបទដ្ឋានដែលនឹងត្រូវបានធ្វើវិសោធនកម្ម។ បង្កាន់ដៃបង់ប្រាក់ដែលបញ្ជាក់អំពីចំនួនទឹកប្រាក់បានបង់ចូលគណនីរបស់ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ព(Print)ចេញ ឬរក្សាទុកឲ្យបានគត់មត់ ដើម្បីជាភស្តុតាងបញ្ជាក់ថាពិតជាបានធ្វើការទូទាត់ប្រាក់រួចហើយ។

ផលិតករ ឬអ្នកនាំចេញ ដែលអញ្ជើញមកនាយកដ្ឋាននាំចេញ-នាំចូល ដើម្បីសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញក្រៅប្រព័ន្ធស្វ័យប្រវត្តកម្ម អាចទូទាត់កម្រៃសេវានៅបញ្ជរបង់ប្រាក់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ដោយផ្ទាល់ ។

ការទូទាត់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារ ត្រូវគិតជាប្រាក់រៀល។ ក្នុងករណី កម្រៃសេវាមួយចំនួនមានកំណត់ជាដុល្លារអាមេរិកនោះ ត្រូវប្តូរមកជាប្រាក់រៀលគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ធនាគារជាតិ នៃកម្ពុជា។

**ប្រការ ៥** :

បន្ទាប់ពីបានទទួលការឯកភាពពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម ផលិតករ ឬអ្នកនាំចេញ ត្រូវបោះពុម្ព(Print)វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" ហើយចុះហត្ថលេខា រួចយកមកនាយកដ្ឋាននាំចេញ-នាំចូល ឲ្យបានឆាប់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មចុះហត្ថលេខា។

ក្នុងករណីដែលផលិតករ ឬអ្នកនាំចេញ មិនអាចបោះពុម្ព(Print)វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" ដោយខ្លួនឯងបាន អាចស្នើសុំឲ្យមន្ត្រីជំនាញនាយកដ្ឋាននាំចេញ-នាំចូល ជួយបោះពុម្ព (Print) ជំនួសបាន។

**ប្រការ ៦** :

ផលិតករ ឬអ្នកនាំចេញ ត្រូវផ្ញើឯកសារច្បាប់ដើមដូចមានកំណត់ខាងក្រោមជូននាយកដ្ឋាននាំចេញ-នាំចូល ដើម្បីផ្ទៀងផ្ទាត់និងតម្កល់ទុក ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃ បន្ទាប់ពីក្រសួងពាណិជ្ជកម្មបានចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរួច៖

**សម្រាប់ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងសម្ភារៈប្រើប្រាស់ផ្សេងទៀតៈ**

- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" (ច្បាប់ថតចម្លង)
- វិក័យប័ត្រ (Invoice)
- តារាងវេចខ្ចប់ (Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of lading)
- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍អាហរណ៍និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

សម្រាប់ផលិតផលសិប្បកម្ម ផលិតផលកសិកម្ម ផលិតផលនេសាទ និងផលិតផលផ្សេងទៀត៖

- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" (ច្បាប់ថតចម្លង)
- វិក័យប័ត្រ (Invoice)
- តារាងវេចខ្ចប់ (Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន
- វិញ្ញាបនបត្របញ្ជាក់បរិមាណទំនិញនាំចេញ(CQ) របស់អគ្គនាយកដ្ឋានកាំកុងត្រូល
- ប្រតិវេទន៍គយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (CD)
- ឯកសារពាក់ព័ន្ធរបស់ក្រុមហ៊ុនដែលបញ្ជាក់ពីប្រភពដើមទំនិញ
- អាជ្ញាប័ណ្ណនាំចេញ (ច្បាប់ថតចម្លង) ចំពោះទំនិញដែលច្បាប់តម្រូវឲ្យមានអាជ្ញាប័ណ្ណនាំចេញ

ក្នុងករណី ដែលផលិតករ ឬអ្នកនាំចេញ មិនបានផ្ញើជូនក្រសួងពាណិជ្ជកម្មនូវឯកសារច្បាប់ដើមដូចមានកំណត់ខាងលើក្រសួងពាណិជ្ជកម្មនឹងមិនបន្តចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញជូនទៀតឡើយ ។

ក្នុងករណី ដែលផលិតករ ឬអ្នកនាំចេញ ផ្ញើជូននូវឯកសារមិនត្រឹមត្រូវ ឬបន្លំឯកសារ ក្រសួងពាណិជ្ជកម្មនឹងចាត់វិធានការតាមផ្លូវច្បាប់។

**ប្រការ ៧** :

ត្រូវបានកំណត់ថិរវេលាសរុបជាអតិបរមាក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់"អេ" រយៈពេល ១១ ម៉ោង ៥៥ នាទី នៃម៉ោងធ្វើការ ផ្អែកតាមតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានដែលនឹងត្រូវបានធ្វើវិសោធនកម្ម។

**ប្រការ ៨** :

ការធ្វើអធិការកិច្ចលើសង្វាក់ផលិតកម្មនិងផលិតផលនាំចេញ ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងវិធានប្រភពដើមទំនិញ ត្រូវធ្វើឡើងដោយមន្ត្រីជំនាញក្រសួងពាណិជ្ជកម្ម ឬដោយមន្ត្រីនៃមន្ទីរពាណិជ្ជកម្មខេត្តនៅមូលដ្ឋានផលិតកម្ម ទីតាំងប្រមូលទិញ និងឃ្លាំងស្តុកទំនិញ មិនឲ្យហួសពី៣០(សាមសិប)ថ្ងៃ បន្ទាប់ពីទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។

**ប្រការ ៩** :

ក្នុងករណី ដំណើរការនៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តកម្មក្នុងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់"អេ" មានភាពរអាក់រអួលផ្នែកបច្ចេកទេស ឬកើតឡើងដោយប្រធានសក្តិ ផលិតករ ឬអ្នកនាំចេញអាចស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" ក្រៅប្រព័ន្ធស្វ័យប្រវត្តកម្ម ។

**ប្រការ ១០** :

មន្ត្រីទទួលបន្ទុកពិនិត្យ និងផ្តល់ការយល់ព្រមលើឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញត្រូវពិនិត្យ ផ្ទៀងផ្ទាត់រាល់ឯកសារយោង ដើម្បីធានាសុក្រឹតភាព និងភាពគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវមុននឹងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញជូនផលិតករ និងអ្នកនាំចេញ។

មន្ត្រីទទួលបន្ទុកពិនិត្យ និងមន្ត្រីអធិការកិច្ច ត្រូវពិនិត្យ ផ្ទៀងផ្ទាត់ឯកសារច្បាប់ដើមដែលផ្ញើមកសង ដោយផលិតករ និងអ្នកនាំចេញ ក្រោយពីបានធ្វើការនាំចេញរួច។

**ប្រការ ១១** :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១២** :

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន តំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស និងប្រធានអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៦ តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

ចម្លងជូនៈ

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរសេវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធស្រូវអង្ករកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

"**ដើម្បីជូនជ្រាប**"

- ដូចប្រការ ១២ "**ដើម្បីអនុវត្ត**"
- ឯកសារ-កាលប្បវត្តិ